ការសាកល្បងសមត្ថភាព ផ្នែកទី៤ បឋមសិក្សាថ្នាក់ទី៦ គណិតវិទ្យា១【៦】 (២)
ប្រាំមួយ ពីរ
ចូលជ្រើសរើសវត្ថុដែលមានផ្ទៃក្រឡាប្រហែល១៥០សង់ទីម៉ែត្រការ៉េ ក្នុងចំណោមលេខ១ ដល់លេខ៤ ខាងក្រោម បន្ទាប់មកសរសេរលេខនោះ។
ផ្ទៃក្រឡារបស់តែមប្រៃសនីយ៍១សន្លឹក
ផ្ទៃក្រឡារបស់កាតប៉ុស្តាល់ឆ្នាំថ្មី១សន្លឹក
ផ្ទៃក្រឡារបស់គម្របសៀវភៅគណិតវិទ្យា១ក្បាល
ផ្ទៃក្រឡារបស់ថ្នាក់រៀន១
តើផ្ទៃក្រឡា១៥០សង់ទីម៉ែត្រការ៉េ មានទំហំប៉ុណ្ណាទៅណ?
បើប្រើបន្ទាត់ដែលមានប្រវែង១៥សង់ទីម៉ែត្រ ប្រហែលជាល្អមសម្រាប់វាស់។
សាកលេខ៤ ផ្ទៃក្រឡារបស់ថ្នាក់រៀនលមើល។ ទេ ទេ តាមពិតមិនអាចវាស់បានទេ។
លេខ១ ផ្ទៃក្រឡារបស់តែមប្រៃសនីយ៍ តែ៣សង់ទីម៉ែត្រ តូចណាស់។
លេខ៣ ផ្ទៃក្រឡារបស់គម្របសៀវភៅ
កំពស់លើសពី១៥សង់ទីម៉ែត្រ។ ទទឹងក៏លើសពី១៥សង់ទីម៉ែត្រ អញ្ចឹងធំជាងច្រើន។
លេខ២ ផ្ទៃក្រឡារបស់កាតប៉ុស្តាល់ឆ្នាំថ្មី
កំពស់ប្រហែល១៥សង់ទីម៉ែត្រ ទទឹង១០សង់ទីម៉ែត្រល្អម។
ចម្លើយគឺលេខ២។
នៅពេលដែលគិតពីលំហាត់ផ្ទៃក្រឡាបែបនេះ យើងគិតតាមការគិតផ្ទៃក្រឡាចតុកោណ រឺការ៉េជាការប្រសើរ។ បន្ទាប់មកយើងគិតទៅលើខ្នាត នៅពេលនោះយើងនឹងអាចរកចម្លើយឃើញ។